សារព័ត៌មានកម្ពុជា ចំណេះដឹងនៃបទពិសោធន៍
Cambodian Journal of Experience Knowledge
*Organized by Share Experience Knowledge Organization (SEKO) - www.bigsek.org*
*Cooperated by SEKO Consulting & Auditing Service (SEKO – CAS) - www.seko.vip*
*Main Sponsored by Cambodian Online Shopping Agency (COSA) - www.cosa.online*

***លេខសំគាល់៖ ១១១៣-១៨១០-២៧០១ ស.ក.ច.ប វគ្គ ១ ភាគ ១/៣ អត្ថបទទី ១/៥ ប្រចាំខែតុលា ឆ្នាំ ២០១៨***
***Serial Number : 1113-1810-2701, CJEK Volume 1, Issue 1 / 3, Article 1 / 5, for October 2018***

ចំណងជើង នៃអត្ថបទនិពន្ធ: <u>យុទ្ធសាស្ត្រ ៣១៣ កំចាត់អំពើលាបពណ៌</u>

កាលបរិច្ឆេទនិពន្ធនិងផលិត: ខែតុលា ឆ្នាំ ២០១៨ (ខ្លឹមសារដើមនិពន្ធ ការកែតម្រូវបែបបទនិពន្ធ និងការបញ្ចប់និពន្ធ)
និពន្ធ និងចែកចាយដោយ : លោក សៀង ប៊ូហឿង ទីប្រឹក្សាយុទ្ធសាស្ត្រ តាមរយៈគម្រោង CJEK នៃអង្គការ SEKO

## ១. អំពី សារព័ត៌មានកម្ពុជា ចែករំលែកចំណេះដឹងនៃបទពិសោធន៍

សារព័ត៌មានកម្ពុជា ចំណេះដឹងនៃបទពិសោធន៍ / Cambodian Journal of Experience Knowledge - CJEK គឺជាគម្រោងអភិវឌ្ឍធនធានមនុស្សតាមរយៈការនិពន្ធ និងចែកចាយអត្ថបទ ក្នុងនាមបុគ្គលដែលជាអ្នកនិពន្ធឯករាជ្យ (មិនមែនក្នុងនាមជាអ្នកសារព័ត៌មានឬក្នុងនាមជាអ្នកកាសែតនោះទេ) ស្តីពីចំណេះដឹងនៃបទពិសោធន៍ដែលទាក់ទងនឹងការសិក្សា ការងារ ស្នេហា និងសង្គម។

CJEK ជាគម្រោងស្នូលរបស់អង្គការចែករំលែកចំណេះដឹងនៃបទពិសោធន៍ (SEKO – www.bigsek.org) ដោយបានសហការជាមួយនឹងគម្រោងនៃ សេវាប្រឹក្សាយោបល់ និងសវនកម្ម សេកូ (SEKO – CAS – www.seko.vip) និងឧបត្ថម្ភគាំទ្រដោយគម្រោងនៃ ភ្នាក់ងារទិញទំនិញតាមប្រព័ន្ធអ៊ីនធឺណេត (COSA – www.cosa.online)។

CJEK មិនមែនជាសារព័ត៌មានបែបកាសែត ឬបែបព្រឹត្តិប័ត្រព័ត៌មាននោះទេ។ ហើយការដែលប្រើពាក្យថា Journal ដែលមានន័យថា "សារព័ត៌មាន" គឺដើម្បីឲ្យស្របទៅនឹងស្តង់ដារអន្តរជាតិ នៃសមាគមន៍ Journal ល្បីៗនៅលើពិភពលោក ដែលធ្វើការនិពន្ធអត្ថបទអប់រំទូទៅ និងជំនាញ ព្រមទាំងការសិក្សាស្រាវជ្រាវផ្សេងៗ។

## ២. អ្វីទៅជា យុទ្ធសាស្ត្រ ៣១៣ កំចាត់អំពើលាបពណ៌?

អំពើលាបពណ៌ ជាទង្វើមួយដែលមនុស្សស្ទើរតែទាំងអស់ជាទូទៅគឺស្អប់វា ហើយរួមទាំងអ្នកដែលចូលចិត្តដើរលាបពណ៌គេ ក៏ស្អប់ទង្វើនេះផងដែរ នៅពេលដែលខ្លួនទទួលរងអំពើលាបពណ៌ពីសំណាៈអ្នកដទៃ។ ហើយពាក្យថា លាបពណ៌ នៅក្នុងនេះមានន័យថា ការប្រឌិតរឿង ការមូលបង្កាច់ និងការកាត់ប្លង់ ឬកាត់តប្លង់ព័ត៌មាន ក្នុងចេតនាទុច្ចរិតណាមួយចំពោះនរណាម្នាក់។

មុននឹងយើងស្គាល់អំពីយុទ្ធសាស្ត្រ ៣១៣ កំចាត់អំពើលាពណ៌ យើងត្រូវធ្វើការស្វែងយល់អំពីអំពើលាបពណ៌ ឲ្យបានច្បាស់លាស់ជាមុនសិន។ រាល់ព័ត៌មានចោទប្រកាន់ ដែលចេញពីអំពើលាបពណ៌ គឺជាព័ត៌មានមិនពិត ប៉ុន្តែដើម្បីជាទម្ងន់ក្នុងការចោទប្រកាន់ទាំងបំពាន អ្នកដើរលាបពណ៌គេតែងតែងរកសាក្សីទាំងពិតនិងសិប្បនិម្មិត រួមទាំងភស្តុតាងទាំងពិត និងមិនពិត ដែលសាកសម្ប និងដែលអាចទៅរួច ទៅតាមលទ្ធភាពរបស់ពួកគេ។

អ្នកអាចនឹងឆ្ងល់ថារាល់ព័ត៌មានចោទប្រកាន់ ដែលចេញពីអំពើលាបពណ៌ គឺជាព័ត៌មានមិនពិត ចុះតើហេតុអ្វីបានជាមានសាក្សីឬ/និងភស្តុតាងខ្លះពិត? តាមពិតទៅ សាក្សីពិតនិងភស្តុតាងពិតទាំងនោះ គឺកើតចេញពីការជំរុញឲ្យមានតាមរយៈឈុតឆាកសម្តែង ដែលរៀបចំឡើងដោយក្រុមទុច្ចរិត នៃអ្នកដើរលាបពណ៌គេនោះតែប៉ុណ្ណោះ។

រីឯ យុទ្ធសាស្រ្ត ៣១៣ កំចាត់អំពើលាបពណ៌ មានន័យថា ទប់ ៣ វ៉ៃ ១ សម្រួល ៣ ដែលរួមមានដូចខាងក្រោម៖

- ទប់ ៣ ៖ លាងព័ត៌មាន លុបព័ត៌មាន និងលាយព័ត៌មាន
- វ៉ៃ ១ ៖ បកស្បែកអ្នកលាបពណ៌
- សម្រួល ៣ ៖ ប្រមូលព័ត៌មាន វិភាគព័ត៌មាន និងវិនិច្ឆ័យព័ត៌មាន

## ៣. របៀប ឬនិតិវិធី ក្នុងការប្រើប្រាស់ យុទ្ធសាស្រ្ត ៣១៣ កំចាត់អំពើលាបពណ៌

របៀប ឬនិតិវិធី ក្នុងការប្រើប្រាស់យុទ្ធសាស្រ្ត ៣១៣ កំចាត់អំពើលាបពណ៌ គឺមានលក្ខណៈជាខួបនៃការអនុវត្តដោយធ្វើសកម្មភាពទប់ ៣ វ៉ៃ ១ និងសម្រួល ៣ ចំពោះការចោទប្រកាន់ដែលមិនពិត រួមទាំងសាក្សី និងភស្តុតាងអម។

នៅពេលដែលយើងទទួលការចោទប្រកាន់ដែលមានលក្ខណៈលាបពណ៌បំភ្លៃការពិតភ្លាម ដំបូងត្រូវសម្រេចចិត្តថាតើត្រូវតប ឬមិនតប នៅក្នុងពេលវេលាជាក់លាក់ ឬបណ្តោះអាសន្នណាមួយ។ មានន័យថា បើត្រូវតប តើគួរត្រូវតបនៅពេលណា? បើមិនតប តើត្រូវអត់ធ្មត់ដល់ពេលណាដែរ? ប៉ុន្តែបើសម្រេចចិត្តច្បាស់ហើយថាត្រូវតបធម្មតាៗ គឺត្រូវប្រើសកម្មភាពទប់ទាំង ៣ រួមមានលាងព័ត៌មាន លុបព័ត៌មាន និងលាយព័ត៌មាន។

ជាទូទៅភាគច្រើននៃអ្នកដើរលាបពណ៌គេ គឺមិនសូវបារម្ភណ៍ចំពោះការតបធម្មតាៗនោះទេ ពីព្រោះបើពួកគេចាញ់ដោយសារការតបនោះ ពួកគេនឹងអះអាងថាវាគ្រាន់តែជាការយល់ច្រលំប៉ុណ្ណោះ ដែលនេះមានន័យថាបើការលាបពណ៌របស់ពួកគេជោគជ័យ ពួកគេនឹងឈ្នះដោយបានធ្វើឲ្យអ្នកដែលត្រូវបានពួកគេលាបពណ៌នោះ នឹងទទួលរងគ្រោះដោយអយុត្តិធម៌ ប៉ុន្តែបើការលាបពណ៌របស់ពួកគេបរាជ័យវិញនោះ ពួកគេនឹងមិនចាញ់ទេ គឺគ្រាន់តែស្មើគ្នា។ ម្យ៉ាងវិញទៀត អ្នកដើរលាបពណ៌គេ គឺកម្រនឹងទទួលស្គាល់កំហុស ដែលកើតពីចេតនារបស់ខ្លួន ក្នុងការលាបពណ៌គេនោះឡើយ។ ដូច្នេះដើម្បីជាការព្រមាន និងទប់ស្កាត់កុំឲ្យកើតមានឡើងម្តងហើយម្តងទៀតទៅថ្ងៃមុខ គប្បីគួរប្រើសកម្មភាពវ៉ៃ ១ ទៅលើអ្នកដើរលាបពណ៌គេនោះ បន្ទាប់ពីទទួលបានប្រសិទ្ធភាពនិងជោគជ័យនៃសកម្មភាពទប់ ៣ រួចហើយ។

គេតែងនិយាយតៗគ្នាថា គ្រូពេទ្យព្យាបាលជម្ងឺជាហើយ ត្រូវចាក់ថ្នាំវ៉ាក់សាំងការពារ ប្រសិនបើចាំបាច់ឬប្រសិនបើមានប្រភេទនៃវ៉ាក់សាំងសម្រាប់ជម្ងឺនោះ។ មិនជាខុសគ្នាទេ នៅពេលដែលយើងប្រើសកម្មភាពវ៉ៃ ១ ធ្វើឲ្យអ្នកដើរលាបពណ៌គេទទួលបរាជ័យ ត្រូវប្រើសកម្មភាពសម្រួល ៣ ដើម្បីធានាឲ្យបានពីសមត្ថភាពភាគីទី ៣ ដែលជាអ្នកស្តាប់ និងដឹងលឺរឿងនេះ ឲ្យមានការយល់ច្បាស់ និងមិនអាចត្រូវបានគេក្លែងបន្លំ ឬបំភាន់ការពិតបាននៅពេលក្រោយ។

ដូច្នេះ តើអ្វីទៅជារបៀប ឬនិតិវិធី ក្នុងការប្រើប្រាស់ យុទ្ធសាស្រ្ត ៣១៣ កំចាត់អំពើលាបពណ៌? ជាការពិតណាស់ ការអនុវត្តយុទ្ធសាស្រ្ត គឺត្រូវមានបច្ចេកទេស និងទេពកោសល្យ ព្រមទាំងភាពក្លាហាន និងឈ្លាសវៃ។ ដូច្នេះសូមស្វែងយល់អំពីរបៀប ឬនិតិវិធី ក្នុងការប្រើប្រាស់ យុទ្ធសាស្រ្ត ៣១៣ កំចាត់អំពើលាបពណ៌ ដូចខាងក្រោម៖

**- ទប់ ៣ ៖ លាងព័ត៌មាន លុបព័ត៌មាន និងលាយព័ត៌មាន**

ក្នុងការលាបពណ៌ តែងតែមានភាគីសរុបចំនួន ៣ ដែលក្នុងនោះរួមមាន៖ ភាគីទី១គឺអ្នកដើរលាបពណ៌គេ ហើយភាគីទី២គឺអ្នកដែលត្រូវបានគេលាបពណ៌ និងភាគីទី៣គឺអ្នកដែលទទួលព័ត៌មានអំពីការលាបពណ៌ ដែលជាអ្នកអាចបង្កផលប៉ះពាល់ ឬផលអាក្រក់ដល់ភាគីទី២ ហើយភាគីទី៣ជាទូទៅគឺស្គាល់ ឬមានទំនាក់ទំនងជាមួយភាគីទី១ និងទី២

ប៉ុន្តែពេលខ្លះ ភាគីទី៣ក៏ជាអ្នកមិនដែលបានស្គាល់ភាគីទី១ និងទី២ពីមុនផងដែរ ដោយទើបតែបានស្គាល់តាមរយៈសកម្មភាពរបស់ភាគីទី១ និងទី២ ក្នុងការបង្កើត ឬបង្កើនចំនួននៃភាគីទី៣ ដើម្បីជាកំលាំងគាំទ្រ ឬកំលាំងទប់ទល់របស់ខ្លួនកាន់តែខ្លាំងឡើងៗ។ បើមានការចោទប្រកាន់ខុសពីការពិត ដោយភាគីទី១ ធ្វើការចោទប្រកាន់ត្រង់ៗទៅភាគីទី២ ដោយផ្ទាល់មួយទល់នឹងមួយ ដែលមិនមែនជាអន្ទាក់ និងមិនពាក់ព័ន្ធជាមួយនឹងភាគីទី៣ណាម្នាក់ទេ នោះមានន័យថា មិនមែនជាអំពើលាបពណ៌នោះទេ គឺគ្រាន់តែជាការយល់ច្រលំ ឬការពិសោធន៍ដើម្បីស្វែងរកការពិតតែប៉ុណ្ណោះ។

ដូច្នេះសកម្មភាពទប់ ៣ របស់ភាគីទី២ គឺត្រូវប្រើចំពោះភាគីទី៣ ដែលទទួលព័ត៌មានអំពីការលាបពណ៌ និងដែលមានសក្តានុពលក្នុងការបង្កផលប៉ះពាល់ ឬផលអាក្រក់ដល់ខ្លួន (មិនមែនជាមួយនឹងភាគីទី១ ដែលជាភាគីបង្កហេតុនោះទេ) ហើយរបៀប ឬនិតិវិធី ក្នុងការប្រើប្រាស់សកម្មភាពទប់៣ មានដូចខាងក្រោម៖

+ **លាងព័ត៌មាន ៖** មានន័យថា ភាគីទី២ត្រូវប្រើប្រាស់កេរ្តិ៍ឈ្មោះ និងទំនុកចិត្តដែលភាគីទី៣មានចំពោះភាគីទី២ ដើម្បីទប់កុំឲ្យទង្វើលាបពណ៌ពីសំណៈភាគីទី១ មានប្រសិទ្ធភាព ឬឥទ្ធិពលអាក្រក់ណាមួយចំពោះភាគីទី២។ ដូច្នេះ អំពើលាបពណ៌នឹងត្រូវបានលាងជម្រះដោយកេរ្តិ៍ឈ្មោះ និងទំនុកចិត្តដែលភាគីទី៣មានចំពោះភាគីទី២ ប៉ុន្តែពេលខ្លះក៏ទាមទារឲ្យភាគីទី២ធ្វើសកម្មភាពដើម្បីជាការរំលឹកដល់ភាភីទី៣ អំពីអតីតកាលដ៏ល្អប្រសើរ ដែលគ្មានថ្ងៃល្អក់កករដូចអ្វីដែលគេបានលាបពណ៌នោះទេ។ ភាគីទី២ត្រូវធ្វើហាក់បីដូចមិនដឹងអ្វីទាំងអស់អំពីការលាបពណ៌ ទោះបីដឹងថាភាគី៣បានព័ត៌មានលាបពណ៌ពីភាគីទី១ហើយក៏ដោយ។ ប្រសិនបើភាគីទី៣បានប្រាប់ឬសួរនាំ ក៏ភាគីទី២ពុំចាំបាច់បកស្រាយ ឬប្រតិកម្មតបដែរ គឺគ្រាន់តែធ្វើធម្មតា មិនភ្ញាក់ផ្អើល និងរក្សាភាពដូចដើមនៃទំនាក់ទំនងរបស់ខ្លួនជាមួយនឹងភាគីទី៣។ គួរឲ្យបញ្ជាក់ផងដែលថា អំពើលាបពណ៌ដែលឈានមកដល់ដំណាក់កាលទប់ទល់នេះគឺមានការចោទប្រកាន់ក្លែងក្លាយ រួមទាំងសាក្សី និងភស្តុតាងទាំងពិត និងប្រឌិត ដូចបានពន្យល់ពីខាងដើម។ ក្នុងករណីដែលសកម្មភាពលាងព័ត៌មានបរាជ័យដោយសារអំពើលាបពណ៌មានសក្តានុពលខ្លាំងជាងកេរ្តិ៍ឈ្មោះ និងទំនុកចិត្តដែលភាគីទី៣មានចំពោះភាគីទី២ នោះភាគីទី២ត្រូវប្រើសកម្មភាពទប់បន្ទាប់ជាបន្ទាន់ គឺលុបព័ត៌មាន។ ហើយបើទោះបីជាសកម្មភាពលាងព័ត៌មានទទួលបានជោគជ័យក៏ដោយ ក៏ត្រូវតែប្រើសកម្មភាពទប់បន្ទាប់ផងដែរ តែមិនបន្ទាន់ទេ គឺត្រូវរង់ចាំឱកាសល្អពេលក្រោយ។ ប៉ុន្តែក្នុងករណីដែលយើងជាអ្នកនយោបាយ ជាបុគ្គលសាធារណៈ ឬជាអ្នករកស៊ីដែលមមាញឹកខ្លាំង ដែលនឹងមិនដួល ឬនឹងមិនអន់ថយ បើទោះបីជាទទួលរងគ្រោះដោយសារអំពើលាបពណ៌នោះ គប្បីគួរបញ្ចប់ត្រឹមហ្នឹង ដែលមានន័យថា យើងត្រូវបោះបង់ចោលនូវការបន្ត យុទ្ធសាស្ត្រ ៣១៣ កំចាត់អំពើលាបពណ៌ ដោយជ្រកក្រោមពាក្យស្លោកមួយដែលថា " គោលដៅនៅខាងមុខ តាមផ្លូវឆ្កែព្រុស បើរវល់គប់ឆ្កែ តើពេលណាទៅ ទើបដល់គោលដៅ?"។

+ **លុបព័ត៌មាន ៖** មានន័យថាលុបពីលើ មិនមែនលុបបំបាត់ ឬបំបិទទេ។ និយាយឲ្យស្រួលយល់ គឺជាការយកព័ត៌មានមួយផ្សេងទៀត ទៅតទល់ជាមួយអំពើលាបពណ៌ ដោយការបដិសេធន៍ ឬច្រានចោលនូវការចោទប្រកាន់ ហើយវាយបកដោយប្រយោលទៅភាគីទី១ តាមរយៈភាគីទី៣ ដើម្បីបន្សាបឥទ្ធិពលនៃការលាបពណ៌។ អ្វីដែលជាបញ្ហា គឺត្រូវធ្វើយ៉ាងណាទើបបានព័ត៌មានដែលជាភស្តុតាង ឬបានព័ត៌មានពីសាក្សីដែលជាអ្នកបានដឹងលឺ បានចាំ និងហ៊ាន ឬព្រមនិយាយការពិត ដើម្បីលុបពីលើព័ត៌មានលាបពណ៌នោះ ក៏ដូចជាដើម្បីបន្សាបឥទ្ធិពលរបស់វា។ ជាជំហ៊ានដំបូង ត្រូវប្រកែក ឬបដិសេធន៍សិន ហើយជំហ៊ានបន្ទាប់ ទើបត្រូវធ្វើការស្វែងយល់ និងទប់ទល់ ដោយព័ត៌មានពិតប្រាកដ។ សាកល្បងគិតតាមន័យត្រង់បន្តិចទៅមើលថាតើបើរថយន្តយើងពណ៌ខៀវ ហើយយើងមានប័ណ្ណសំគាល់រថយន្តត្រឹមត្រូវ តែត្រូវបានគេយកទៅលាបព័ណក្រហមពីលើ ហើយចោទថាយើងលួចរថយន្តរបស់គេ។ តើត្រូវធ្វើដូចម្តេច? ជាការពិត យើងអាចធ្វើការផ្ទៀតផ្ទាត់លេខតួម៉ាស៊ីន។ ប៉ុន្តែបើនិយាយពីពណ៌រថយន្តវិញ បើយើងចង់កែឲ្យទៅជាពណ៌ខៀវវិញ

ដោយលាងពណ៌ក្រហមនោះចេញ ពិតជាពិបាកណាស់ គឺមានតែលាបពណ៌ខៀវពីលើពណ៌ក្រហមនោះតែប៉ុណ្ណោះ។ ដូច្នេះយើងត្រូវតែមាន ឬអាចរកបាននូវពណ៌ខៀវដែលដូចពីមុនទាំងស្រុង ឬស្រដៀងគ្នាខ្លាំង បើមិនបានដូច ១០០%!

+ **លាយព័ត៌មាន ៖** បើយើងចាក់ទឹកថ្នាំពណ៌ខៀវចូលទៅក្នុងកែវដែលមានទឹកធម្មតាពកន្លះកែវ នោះទឹកនៅក្នុងកែវនឹងប្រែជាពណ៌ខៀវ។ បន្ទាប់មក បើយើងចាក់ថែមទឹកថ្នាំពណ៌លឿងលាយចូលគ្នាជាមួយពណ៌ខៀវ វានឹងប្រែជាពណ៌បៃតង។ ដូចគ្នាផងដែរ នៅពេលដែលគេលាបពណ៌យើង តែយើងបែរជានិយាយបន្ថែមបែបលេងសើច ដោយបន្ថែមភាពមិនពិត ពីលើភាពមិនពិត នោះការលាបពណ៌នឹងត្រូវបន្សាបឥទ្ធិពលដោយឯងៗ និងគ្រប់គ្រងលេងបាន។ ឧទាហរណ៍ គេថាយើងយកដុំថ្មវាយកូនគេបែកក្បាលកាលពីថ្ងៃមុន យើងត្រូវថាមិនមែនត្រឹមតែដុំថ្មទេ នៅមានយកពូថៅទម្ងន់១០គីឡូក្រាមកាប់ចំកណ្ដាលក្បាលទៀតផល សំណាងហើយមិនស្លាប់។ ហា.ហា.ហា... តែត្រង់ចំណុចនេះត្រូវប្រយ័ត្នរងគ្រោះដោយសារល្បិចឈឺសាច់! ការបន្ថែមព័ត៌មានលាបពណ៌ ត្រូវប្រាកដថាជាលក្ខខណ្ឌដែលមិនអាចទៅរួច។ បើសិនយើងថាមិនមែនត្រឹមតែដុំថ្មទេ នៅមានយកដំបងសំពោងក្បាលឬនៅមានយកកូនកំបិតកាប់ក្បាល ហើយស្រាប់តែគេស្ម័គ្រចិត្តប្រើល្បិចឈឺសាច់ ទៅថែមខ្លួនឯងតាមការនិយាយរបស់យើង រួចបកមកនិយាយចោទថាពិតមែនហើយ តែគេនៅនិយាយមិនទាន់អស់ នោះយើងប្រាកដជាវីវរហើយ ពីព្រោះការនិយាយរបស់យើង នឹងក្លាយជាការសារភាពដោយអចេតនា និងទាំងមិនបានប្រព្រឹត្ត តែត្រូវប្រឈមនឹងការជាប់ទោស។

- **វ៉ៃ ១ ៖ បកស្បែកអ្នកលាបពណ៌**

ឈានមកដល់ដំណាក់កាលនេះហើយ មិនគួរបកក្រោយទេ។ បើឈប់ពាក់កណ្ដាលទី នោះអ្នកដើរលាបពណ៌គេនឹងបានចិត្ត ហើយអាចនឹងសុំនឹង យុទ្ធសាស្ត្រ ៣១៣ កំចាត់អំពើលាបពណ៌ ដែលប្រៀបដូចទៅនឹងការផឹកថ្នាំផ្សះមិនគ្រប់ចំនួនជាដាច់ ពីព្រោះបានជាហើយក៏ឈប់ផឹកភ្លាមទោះនៅសល់ថ្នាំដែលពេទ្យបានកំណត់ឲ្យផឹក ទើបធ្វើឲ្យជម្ងឺស៊ាំជាមួយថ្នាំ ដែលជាហេតុត្រូវដូរប្រភេទថ្នាំផ្សះដែលធ្លាប់ប្រើរួចពីមុន សម្រាប់ការឈឺលើកក្រោយៗ។ ហើយសកម្មភាពបកស្បែកអ្នកលាបពណ៌នេះ គឺវ៉ៃសំដៅត្រង់ៗទៅភាគីបង្កដែលជាអ្នកដើរលាបពណ៌គេ ដោយផ្ទាល់និងដោយប្រយោលតាមរយៈភាគីទី៣ ដែលជាអ្នកដឹងលឺ ដោយត្រូវវែកញែកឲ្យដឹងខុសត្រូវ ដើម្បីបញ្ជាក់ថាភាគីទី១ ឬភាគីបង្ក គឺពិតជាមនុស្សអាក្រក់ដែលបានដើរលាបពណ៌គេដោយចេតនាសុទ្ធសាធ និងមិនមែនជាការភាន់ច្រលំស្អីទេ។ អាចជាការភាន់ច្រលំរបស់ភាគីទី១ លុះត្រាតែមានការសុំទោសពិតប្រាកដចំពោះការភាន់ច្រលំរបស់ខ្លួនដែលជាភាគីបង្ក នៅចំពោះមុខភាគីទី៣ ។ ត្រូវយកភស្តុតាង ឬសាក្សី និងលទ្ធផលចុងក្រោយទៅបញ្ជាក់ ដើម្បីជាការបកស្បែកអ្នកលាបពណ៌គេនោះ! សកម្មភាពបកស្បែក គឺត្រូវធ្វើចំពោះទាំងការចោទប្រកាន់គ្មានការពិត និងចំពោះភស្តុតាង រួមទាំងសាក្សីអមជាទម្ងន់ក្នុងការចោទប្រកាន់នោះ ដែលជាសកម្មភាស្នូល និងអនុសកម្មភាពរបស់អំពើលាបពណ៌។ គួរឲ្យបញ្ជាក់ផងដែរថាការចោទប្រកាន់ គឺខុសពីការសង្ស័យ ហើយអំពើលាបពណ៌ គឺសំដៅទៅលើការចោទប្រកាន់ដែលមិនពិត។ ការចោទប្រកាន់ត្រូវមានសកម្មភាពវាយត្រឡប់ទៅវិញ ដោយឡែកការដាក់ការសង្ស័យ គឺត្រូវមានការស្វែងយល់បន្ថែម ប៉ុន្តែពុំត្រូវមានសកម្មភាពវាយត្រឡប់ទៅវិញនោះទេ។ ដូច្នេះការសង្ស័យទាំងឡាយណា ដែលមានសកកម្មភាពវាយត្រឡប់ទៅវិញ នោះគឺស្មើនឹងការចោទប្រកាន់ បើទោះបីជាប្រើពាក្យសង្ស័យ។ ឧទារហរណ៍ថា ថៅកែបានសង្ស័យថាបុគ្គលិកម្នាក់លួចលុយ ហើយបានបណ្ដេញដោយហេតុផលលួច ឬចាត់វិធានការផ្សេងៗដើម្បីបណ្ដេញដោយប្រយោលនៃហេតុផលលួច នោះគេហៅថាជាការចោទប្រកាន់ ដែលជ្រកក្រោមពាក្យថាសង្ស័យ។ រាល់ការសង្ស័យ គឺត្រូវស្វែងយល់ តាមដាន និងរកភស្តុតាង ព្រមទាំងសាក្សី។ ម្យ៉ាងវិញទៀតបើមានការសង្ស័យ អាចរៀបសកម្មភាពការពារខ្លួន តែរាល់សកម្មភាពការពារខ្លួនដែលប៉ះពាល់ដល់អ្នកដែលត្រូវបានគេសង្ស័យ នោះនឹងត្រូវបានចាត់ទុកជាសកម្មភាពវាយត្រឡប់ទៅវិញ។

- សម្រួល ៣ ៖ ប្រមូលព័ត៌មាន វិភាគព័ត៌មាន និងវិនិច្ឆ័យព័ត៌មាន

បើទោះបីជាបានបកស្បែកអ្នកដើរលាបពណ៌គេដោយជោគជ័យហើយក៏ដោយ សកម្មភាពសម្រួល ៣ គឺប្រៀបបានទៅនឹងថ្នាំវ៉ាក់ស៊ាំងការពារជម្ងឺ កុំឲ្យកើតមានឡើងម្ដងទៀត បន្ទាប់ពីទើបតែបានព្យាបាលឲ្យជាសះស្បើយរួច។ សកម្មភាពសម្រួល ៣ នេះគឺត្រូវធ្វើចំពោះខ្លួនឯងដែលជាភាគីទី ២ និងចំពោះភាគីទី ៣ ដោយត្រូវធ្វើការសិក្សាយកជាបទពិសោធន៍អំពីរឿងដែលកន្លងហួសទៅ តាមរយៈការពិភាក្សានិងជជែកគ្នាលេងអំពីការប្រមូលព័ត៌មាន វិភាគព័ត៌មាន និងវិនិច្ឆ័យព័ត៌មាន ដ៏ត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។ ក្នុងសម័យទំនើបនិងរីកចម្រើននាពេលបច្ចុប្បន្ននេះ មានពេលខ្លះ សូម្បីតែអ្វីដែលយើងបានលឺផ្ទាល់ត្រចៀក និងឃើញផ្ទាល់ភ្នែក ក៏អាចមិនមែនជាការពិតដែរ។ ដូច្នេះ ជំនាញក្នុងការប្រមូល វិភាគ និងវិនិច្ឆ័យព័ត៌មាន គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការស្វែងរកការពិត។

+ **ប្រមូលព័ត៌មាន** ៖ ជាទូទៅ ព័ត៌មានឬទិន្នន័យត្រូវបានចែកចេញជា ២ ប្រភេទ គឺព័ត៌មានឆៅ និងព័ត៌មានឆ្អិន។ ព័ត៌មានឆៅ សំដៅទៅលើព័ត៌មានច្បាប់ដើមដែលមិនទាន់ឆ្លងកាត់ការវិភាគ និងការកែតម្រូវ ព្រមទាំងមិនទាន់បានចេញផ្សាយដើម្បីចែកចាយបន្ត។ រីឯព័ត៌មានឆ្អិន សំដៅទៅលើព័ត៌មានដែលទទួលបានបន្តឬព័ត៌មានដែលបានឆ្លងកាត់ការវិភាគ ឬព័ត៌មានដែលបានឆ្លងកាត់ការសង្ខេប ឬជាព័ត៌មានដែលបានចែកចាយបន្តរួចហើយ។ នៅពេលទៅប្រមូលព័ត៌មាន ត្រូវដឹងថាតើវាជាព័ត៌មានប្រភេទមួយណា ហើយបើជាព័ត៌មានឆ្អិន ត្រូវផ្ដោតការយកចិត្តទុកដាក់ឲ្យខ្លាំងបន្តិច ពីព្រោះនៅពេលខ្លះសូម្បីតែព័ត៌មានឆៅ ក៏នៅតែអាចក្លែងក្លាយផង។ ការប្រើញាណទាំងប្រាំរបស់មនុស្ស រួមនឹងបច្ចេកវិទ្យាទំនើប ដោយមានផែនការច្បាស់លាស់ និងភាពប៉ិនប្រសប់ គឺជាកត្តាអំណោយផលបំផុតក្នុងការប្រមូលព័ត៌មាន ហើយព្យាយាមយកតែព័ត៌មានឆៅ។ ជាធម្មតាអ្នកដើរលាបព័ត៌គេ គឺចូលចិត្តប្រើព័ត៌មានឆ្អិនភាគច្រើន រួមនិងព័ត៌មានឆៅភាគតិច។ ដូច្នេះនៅពេលទទួលបានបានព័ត៌មានដែលចេញពីអ្នកដើរលាបពណ៌ និងនៅពេលប្រមូលព័ត៌មានពីភាគីផ្សេងៗដែលពាក់ព័ន្ធ ត្រូវរៀបចំរក្សាទុកដោយបែងចែកឲ្យបានត្រឹមត្រូវរវាងព័ត៌មានឆៅ និងព័ត៌មានឆ្អិន។

+ **វិភាគព័ត៌មាន** ៖ ការវិភាគព័ត៌មាន គឺត្រូវពឹងទៅលើព័ត៌មានដែលប្រមូលបាន និងការស្គាល់ចរិតលក្ខណៈរបស់អ្នកផ្ដល់ព័ត៌មាន ហើយបន្ទាប់មកធ្វើការសង្ខេបព័ត៌មានឆៅ និងធ្វើការស្វែងយល់ពីបុព្វហេតុនៃព័ត៌មានឆ្អិន ដើម្បីឈានទៅដល់ការកំណត់អំពីព័ត៌មានច្បាស់ការដែលមានភាពពិត និងអាចទុកចិត្តបាន។ នៅពេលវិភាគ ត្រូវចេះយកជំនាញព្រមទាំងបទពិសោធន៍ ទៅប្រើញាណទាំងប្រាំរួមនិងបច្ចេកវិទ្យា ដោយជៀសជាងការយកអារម្មណ៍លំអៀងគ្មានការពិត និងអយុត្តិធម៌ ទៅបញ្ច្រាញាណទាំងប្រាំរួមនិងបច្ចេកវិទ្យា ឲ្យចេញលទ្ធផលស្របតាមគំនិតរបស់ខ្លួនទាំងបំពានការពិត។ លទ្ធផលនៃការវិភាគសរុបឬជារួម គឺត្រូវមានជំនឿជឿជាក់លើសពី ៨០% តែកុំឲ្យដល់ ១០០% និងត្រូវមានសេនារីយ៉ូ ឬជម្រើសចាប់ពី ២ ឡើងទៅ ដែលសេនារីយ៉ូនីមួយៗត្រូវមានជំនឿជឿជាក់ស្ថិតនៅចន្លោះពី 0% រហូតដល់ ៨0%។

+ **វិនិច្ឆ័យព័ត៌មាន** ៖ មកដល់ដំណាក់កាលនេះ គឺត្រូវយកសេនារីយ៉ូទាំងអស់ដែលទទួលបានក្រោយពីការវិភាគមកសម្រេចចុងក្រោយថាតើមួយណាជាជម្រើសត្រឹមត្រូវជាងគេបំផុត បន្ទាប់ពីបានផ្ទៀងផ្ទាត់ជាមួយព័ត៌មានថ្មីៗបន្ថែមដែលបានពីសាក្សី ឬភស្តុតាងផ្សេងៗដែលទើបទទួលបាន ឬទើបធ្វើការវិភាគស៊ីជម្រៅបន្ថែមទៀត។ ត្រង់ចំណុចនេះ មិនប្រាកដថាសេនារីយ៉ូ ដែលមានភាគរយជឿជាក់ច្រើនជាងគេ ត្រូវបានសម្រេចជ្រើសរើសចុងក្រោយនោះទេ ហើយពេលខ្លះអាចអត់យកទាំងអស់ ក៏មានដែរ ដោយមានសេនារីយ៉ូថ្មីទៀត ក៏ថាបានដែរ។ ការវិនិច្ឆ័យ ជាការវិភាគស៊ីជម្រៅ និងការសម្រេចចិត្តដ៏ត្រឹមត្រូវបែបយុទ្ធសាស្ត្រ តែឥតលម្អៀង។ ហើយក្រោយពីការវិនិច្ឆ័យ ទោះមានការជឿជាក់ខ្ពស់យ៉ាងណាក៏ដោយ ក៏អាចមានការប្រែប្រួលក្នុងកម្រិតភាគរយចន្លោះពី0% ទៅ ៥% ផងដែរ។ អញ្ចឹងហើយ ទើបនៅក្នុងការរស់នៅសព្វថ្ងៃ មានតុលាការសាលាដំបូង តុលាការសាលាឧទ្ធរណ៍ និងតុលាការសាលាកំពូល។

## ៤. លក្ខខណ្ឌ និងគោលការណ៍ សម្រាប់អ្នកប្រើប្រាស់ យុទ្ធសាស្ត្រ ៣១៣ កំចាត់អំពើលាបពណ៌

- លក្ខខណ្ឌសំខាន់ៗ សម្រាប់អ្នកប្រើប្រាស់ យុទ្ធសាស្ត្រ ៣១៣ កំចាត់អំពើលាបពណ៌
  + អ្នកប្រើប្រាស់យុទ្ធសាស្ត្រនេះ ត្រូវមានជំនាញជីវិតក្នុងការរស់នៅ ក៏ដូចជាការប្រាស្រ័យទាក់ទងក្នុងសង្គម។
  + អ្នកប្រើប្រាស់យុទ្ធសាស្ត្រនេះ ត្រូវមានបទពិសោធន៍ជីវិតនៃការរស់នៅ និងភាពទន់ភ្លន់តែមិនទន់ជ្រាយ។
  + អ្នកប្រើប្រាស់យុទ្ធសាស្ត្រនេះ ត្រូវស្វែងយល់ឲ្យបានទូលំទូលាយអំពីយុទ្ធសាស្ត្រនេះ ឲ្យទាន់សម័យកាល។
- គោលការណ៍សំខាន់ៗ សម្រាប់អ្នកប្រើប្រាស់ យុទ្ធសាស្ត្រ ៣១៣ កំចាត់អំពើលាបពណ៌
  + ត្រូវយកទៅប្រើប្រាស់ដើម្បីការពារគេលាបពណ៌ មិនមែនយកទៅការពារទង្វើអាក្រក់ពិតៗរបស់ខ្លួននោះទេ។
  + ត្រូវយកទៅចែកចាយ និងបង្រៀនដល់អ្នកដទៃដើម្បីការពារខ្លួនកុំឲ្យរងគ្រោះដោយសារមានគេលាបពណ៌។
  + ត្រូវយកទៅប្រើជាប្រយោជន៍ក្នុងការប្រឹក្សា ឬផ្តល់យោបល់ដល់ជនរងគ្រោះដោយសារមានគេលាបពណ៌។

## ៥. សេចក្តីសន្និដ្ឋាន

ខ្លឹមសារដូចបានបកស្រាយ និងពន្យល់ពីខាងលើ នឹងជាប្រយោជន៍សម្រាប់អ្នកអាន ដើម្បីយកជាមូលដ្ឋានក្នុងការសិក្សាស្វែងយល់បន្ថែមអំពី យុទ្ធសាស្ត្រ ៣១៣ កំចាត់អំពើលាបពណ៌ មុននឹងឈានដល់ការប្រើប្រាស់យុទ្ធសាស្ត្រនេះ ដោយត្រូវគោរពតាមលក្ខខណ្ឌ និងគោលការណ៍ សម្រាប់អ្នកប្រើប្រាស់ យុទ្ធសាស្ត្រ ៣១៣ កំចាត់អំពើលាបពណ៌។

## ៦. ការផ្តល់អនុសាសន៍

- គប្បីគួរអានហើយអានទៀតរហូតដល់យល់ និងត្រូវស្វែងយល់អំពីពាក្យពេចន៍ដែលបានបង្កប់អត្ថន័យផ្សេងៗ។
- បើរៀនចេះអស់ហើយ គប្បីគួរអនុវត្តជាក់ស្តែង ដើម្បីឲ្យកាន់តែមានភាពស្ទាត់ជំនាញថែមទៀត។
- ហើយបើចេះស្ទាត់ជំនាញហើយ គប្បីគួរចេះជួយគេ និងចែកចាយបន្តឲ្យគេរៀនដើម្បីចេះផង គ្រាន់បានជាគ្នា។

## ៧. ឯកសារយោង

(គ្មានឯកសារយោង ពីព្រោះនេះជាអត្ថបទនិពន្ធតាមពិសោធន៍ ដោយគ្មានការដកស្រង់ចេញពីប្រភពណាមួយឡើយ។)

*ថ្ងៃច័ន្ទ ៥រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០១៨*
**និពន្ធ និងចែកចាយដោយ**

**លោក សៀង ប៊ុហឿង**
**ទីប្រឹក្សាយុទ្ធសាស្ត្រ**